**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប**
**ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)**
**លេខាធិការដ្ឋាន**
លេខ: ៤៤២ ស.ជ ....គ.ជ.អ.ប

ថ្ងៃ សុក្រ ៨ កើត ខែ មិគសិរ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២៥

## ជម្រាបជូន

### លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

**កម្មវត្ថុ** ៖ សំណើសុំចាត់ចែងផ្តល់សំណុំឯកសារជាច្បាប់ថតចម្លងដល់ការិយាល័យអប់រំ យុវជន និងកីឡា ដើម្បីចុះកិច្ចបញ្ជិកាគណនេយ្យក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា (EFMS)។

**យោង** ៖ លិខិតលេខ ៥៦៩០ អយក.ហវ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក លោកស្រីអភិបាល** ជ្រាបថា ផ្អែកតាមលិខិតរបស់ក្រសួងអប់រំយុវជន និងកីឡា បានស្នើមកលេខាធិការដ្ឋាន គ.ជ.អ.ប. ជួយសម្របសម្រួលឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌផ្តល់នូវសំណុំឯកសារមាន អាណាប័ណ្ណ (អាណត្តិបើកប្រាក់ អាណត្តិនិយ័តកម្ម និង/ឬប្រតិបត្តិការចំណាយ (Voucher) ចេញពីប្រព័ន្ធ FMIS និងលិខិតយុត្តិការចំណាយជាច្បាប់ថតចម្លង ឬស្កេនសម្រាប់កត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុចូលប្រព័ន្ធ EFMS ជូនដល់ការិយាល័យអប់រំ យុជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ដើម្បីមានមូលដ្ឋានចុះកិច្ចបញ្ជិកាគណនេយ្យថវិកាថ្នាក់ជាតិ គណនេយ្យថវិកាថ្នាក់ក្រោមជាតិ ការកាន់បញ្ជីចំណូល-ចំណាយប្រាក់ដែលបានបើកផ្តល់មុន និងការទូទាត់ចំណាយរបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈសម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ។

ក្នុងន័យនេះ ដើម្បីធានាឱ្យការអនុវត្តមុខងារវិស័យអប់រំ យុវជន និងកីឡា ដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងមានសង្គតិភាពជាមួយនីតិវិធីនៃការចុះកិច្ចបញ្ជិកាគណនេយ្យដែលបានណែនាំក្នុងប្រកាសអន្តរ



លេខាធិការដ្ឋាននៃគ.ជ.អ.ប ៖ ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ អគារ (V) មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
National Committee for Sub-National Democratic Development Secretariat (NCDDS): Located in Ministry of Interior (Building V) Norodom Bvl., Tonle Bassac Sangkat, Chamkarmon Khan, Phnom Penh Kingdom of Cambodia Email: info@ncdd.gov.kh Website: www.ncdd.gov.kh

ក្រសួងលេខ ៣៨៥ សហវ.ប្រក.អថ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ និងសារាចរលេខ ០០២សហវ.ស.រ.អគេន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការចុះកិច្ចបញ្ជិកាគណនេយ្យត្រូវមានភ្ជាប់សំណុំឯកសារជាចាំបាច់មាន អាណាប័ណ្ណ (អាណត្តិបើកប្រាក់ អាណត្តិនិយ័តកម្ម និង/ឬប្រតិបត្តិការចំណាយ (Voucher) ចេញពីប្រព័ន្ធ FMIS និងលិខិតយុត្តិកាចំណាយជាច្បាប់ថតចម្លង ឬស្កេនសម្រាប់កត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុចូលប្រព័ន្ធ EFMS ជាប្រចាំដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយភាពគ្រប់ជ្រុងជ្រោយ។

អាស្រ័យដូចបានជម្រាបខាងលើ លេខាធិការដ្ឋាន គ.ជ.អ.ប. សូមស្នើ **លោក លោកស្រីអភិបាល** ចាត់ចែងផ្តល់សំណុំឯកសារជាច្បាប់ថតចម្លងដល់ការិយាល័យអប់រំ យុវជន និងកីឡា ដើម្បីចុះកិច្ចបញ្ជិកាគណនេយ្យក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា (EFMS)។

សូម **លោក លោកស្រីអភិបាល** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ៕

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា**
**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

ចាន់ សុធា

លេខ: ១៤៣៤ អយក.ចល
**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃ............ខែ............ឆ្នាំ............ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០២៥
**តប.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**អគ្គលេខាធិការ**

ឆេព តិយ្យោរិទ្ធ